**BBI0100**

# សម្ភាសន៍ជាមួយឈ្មោះ ទេព ធឿន ភេទប្រុស អាយុ៥៧ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហមៈ យោធា

ស្រុកកំណើតនៅភូមិគគរ ឃុំគគរ ស្រុកក្រូចេះ ខេត្តក្រចេះ

រស់នៅភូមិសាស្តា ឃុំសាស្តា ស្រុកសំពៅលូន ខេត្តបាត់បង

ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ស សេងគា

០០:៤៩:២៥

២២ទំព័រ

សេងគា ៖ អឺចឹងជាដំបូងខ្ញុំជំរាបពូម្តងទៀតខ្ញុំឈ្មោះ សេងគា ខ្ញុំធ្វើការខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំអ្នកស្រុកបាត់ដំបងនេះទេអ្នកស្រុកឯកភ្នំ ហើយមកនេះគោលបំណងរបស់ខ្ញុំគឺចង់សម្ភាសន៍ពីរឿងរ៉ាវរបស់ពូ តាំងពីនៅក្មេងរហូតដល់សម័យសង្គ្រាម ហើយរហូតដល់បច្ចុប្បន្នហ្នឹង តើពូជួបប្រទះនូវបទពិសោធន៍អ្វីខ្លះ ហើយជួបការលំបាកយ៉ាងម៉េចខ្លះ ហើយបន្ទាប់មកទៀតដំណាក់កាលៗមានរដ្ឋប្រហារលន់ នល់ បន្ទាប់មកទៀតសម័យខ្មែរ ក្រហម៧៥ដល់៧៩ហ្នឹងៗអឺចឹងជាដំបូងចង់ឲ្យពូរៀបរាប់ អាចចាំបានប៉ុណ្ណាយកប៉ុន ហ្នឹងសិន បន្ទាប់មកចាំខ្ញុំសួរពូបន្ថែមទៀត?

ធឿន ៖ បាទ! ខ្ញុំឈ្មោះ ទេព ធឿន មានភូមិកំណើតនៅភូមិគគរ ឃុំគគរ ស្រុកក្រចេះ ខេត្តក្រចេះៗ ខ្ញុំមានបងប្អូន១១នាក់ ប៉ុនឪពុកម្តាយស្លាប់អស់ហើយ ហើយខ្ញុំនៅពីក្មេងខ្ញុំរៀននៅសាលាបឋមសិក្សាគគរ បន្ទាប់មករៀននៅវិទ្យាល័យក្រចេះ វិទ្យាល័យព្រះកុសមៈក្រចេះ រៀនបានដល់ថ្នាក់ទី៨ពីដើម មកទល់សម័យឆ្នាំ៧០ដល់រដ្ឋប្រហារក៏ឈប់រៀនតាំងពីហ្នឹងមក ដល់ឈប់រៀនទៅក៏នៅធ្វើស្រែៗ របររកស៊ីកាលហ្នឹងមានតែធ្វើស្រែចំការជាមួយឪពុកម្តាយហ្នឹង ហើយបានដល់ឆ្នាំ៧៤ៗក៏បានគេរើសជាសម័យនេះយើងសម័យខ្មែរក្រហមហ្នឹង ៧៤គេរើសជាកងចល័ត កងចល័តខ្ញុំក៏ចូលក្នុងកងចល័តឆ្នាំ៧៤ហ្នឹង ហើយបានធ្វើការរហូតទៅដល់ កងចល័តនៅបាន២ឆ្នាំបានមកនៅផ្គត់ផ្គង់ស្រុកក្រចេះ ហើយនៅបាន១ឆ្នាំ២ឆ្នាំមកចុងឆ្នាំ៧៨ហ្នឹង គេដកខ្ញុំមកហៅថា កងចល័តទៀត កងចល័តៗបង្កបង្កើនផលជំនាន់នោះ បាទ!នៅកងចល័តរហូតបានរៀតណាមចូលឆ្នាំ៧៩ៗ ហើយឆ្នាំ៧៩ហ្នឹងក៏ទៅរស់នៅជាមួយអង្គភាពកងទ័ព

ខេត្តក្រចេះ នៅអង្គភាពកងទ័ពខេត្តក្រចេះនៅតាមព្រៃព្រំប្រទល់ខេត្តក្រចេះ មណ្ឌលគីរី ព្រំប្រទល់ខេត្តស្ទឹងត្រែងអាហ្នឹងក្នុងព្រៃហើយ កាលជំនាន់៧៩ហ្នឹង ក្រោយពីវៀតណាមចូលមកវានៅក្នុងព្រៃៗ រស់នៅក្នុងព្រៃហ្នឹងជាយូរឆ្នាំដែរ បានឆ្នាំ៨១ក៏ខាងលើតម្រូវឲ្យអង្គភាពកងទ័ពខេត្តក្រចេះហ្នឹង មកនៅតាមខាងលិចទន្លេជួរភ្នំដងរែក... អាហ្នឹងឆ្នាំ៨១ខ្ញុំឆ្លងទន្លេមកនៅខាងភ្នំដងរែកឆ្នាំ៨១ ហ្នឹងដើរដេកក្នុងព្រៃៗរហូត អត់មានភូមិករអីទេកាលហ្នឹងរស់តែក្នុងព្រៃ ហើយបានដល់ឆ្នាំ៨៤ខាងតម្រូវឲ្យខ្ញុំមកខាងជួរភ្នំក្រវាញ ក៏នៅតាមព្រៃដែរ មិនទាន់មានភូមិករអីដូចឥឡូវនេះទេ ហើយបានឆ្នាំ៨៩ ខ្ញុំមកនៅប៉ៃលិនបានជាង១ឆ្នាំ បានឆ្នាំ៩០ខ្ញុំមកនៅខាងម្តុំយើងនេះខាងកើត នៅបានប៉ុន្មានដល់ឆ្នាំ៩៦បានមានការផ្តាច់ខ្លួន បានមករស់លើទឹកដីនេះរហូតដល់ឥឡូវនេះ មានភូមិករ មានផ្ទះសម្បែង មានដីចំការបង្កបង្កើនផល ហ្នឹងប្រវត្តិសង្ខេបៗខ្លីពីមុនខ្ញុំរៀបរាប់ប៉ុនហ្នឹង ។

សេងគា : បាទ!អីចឹងខ្ញុំសួរបញ្ជាក់បន្ថែមទៀត មុននឹងសម្ភាសន៍ពូ ខ្ញុំប្រាប់ពីគោលបំណងរបស់ខ្ញុំយកឯកសារនេះទៅចងក្រងជាឯកសារ ជាប្រវត្តិសាស្ត្រឲ្យក្មេងៗជំនាន់ក្រោយបានរៀនសូត្រ និងប្រើប្រាស់ដូចជា សរសេរចុះក្នុងទស្សនាវដ្តីស្វែងរកការពិតខាងកន្លែងខ្ញុំពូអត់ថាអីទេពូ?

ធឿន : បាទ!

សេងគា : មិញស្រុកកំណើតរបស់ពូនៅភូមិគគរ ឃុំគគរ ស្រុកក្រចេះ ខេត្តក្រចេះ?

ធឿន : បាទ!ស្រុកក្រចេះ ខេត្តក្រចេះ ។

សេងគា : បច្ចុប្បន្ននៅក្នុងភូមិអីគេពូ?

ធឿន : យើងនេះភូមិសាស្តា ឃុំសាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

សេងគា : ឪពុកពូឈ្មោះអីពូ?

ធឿន : ឪពុកខ្ញុំឈ្មោះ ទេព កើត ។

សេងគា : គាត់ស្លាប់ហើយឬនៅ?

ធឿន : ស្លាប់ហើយ ។

សេងគា : ស្លាប់ដោយសារអីដែរកាលហ្នឹង?

ធឿន : ស្លាប់នៅរបបខ្មែរក្រហម សម័យ៣ឆ្នាំ ។

សេងគា : ម៉េចបានគាត់ស្លាប់កាលហ្នឹង?

ធឿន ៖ កាលហ្នឹងគេចោទគាត់ពិការស្អីៗ គេមិនដឹង កាលហ្នឹងខ្ញុំចេញពីគាត់ផុតហើយ ។

សេងគា ៖ ចុះម៉េចបានពូដឹងថាគាត់ស្លាប់?

ធឿន ៖ ចុះយើងមកដល់បានជួបជុំបងប្អូន និយាយប្រាប់ ។

សេងគា ៖ មានបងប្អូនប្រាប់ថាស្លាប់ដោយសារអីគេកាលហ្នឹង?

ធឿន ៖ កាលហ្នឹងគេចាប់យកទៅដល់មណ្ឌលឃុំឃាំង គេថាស្លាប់ មិនដឹងស្លាប់ដោយរបៀបម៉េចទេមិនដឹង ។

សេងគា ៖ អ្ហូ!អ្នកណាគេអ្នកប្រាប់ បងប្អូនហ្នឹងឈ្មោះអី?

ធឿន ៖ ភូមិករហ្នឹងដឹងទាំងអស់ហ្នឹង ។

សេងគា ៖ ឪពុកពូកាលពីដើមគាត់ធ្វើអីដែរ?

ធឿន ៖ កាលពីដើមធ្វើជាគ្រូបង្រៀននៅសាលាឯកជនចិនទេ គាត់មានធ្វើទាហានក្នុងក្របខ័ណ្ឌរាជការទេ សាលាក្របខ័ណ្ឌឯកជនចិន ។

សេងគា ៖ បាទ!នៅក្រចេះហ្នឹងពូ?

ធឿន ៖ បាទ! នៅក្រចេះ ។

សេងគា ៖ សាលាចិនហ្នឹងឈ្មោះអីគេ?

ធឿន ៖ សាលាឯកជនចិនចឹងហ្មង គេដាក់សាលាឯកជន ពីមុនមានសាលាចិន មានសាលាខ្មែរ ។

សេងគា ៖ កាលហ្នឹងគេចាប់នៅឆ្នាំ៧០ប៉ុន្មានពូ គេចាប់ហ្នឹង?

ធឿន ៖ ឆ្នាំ៧៨ ។

សេងគា ៖ អ្ហូ!ពេលដែលគេចោទសោ ភីម អីហើយហ្នឹងពូ?

ធឿន ៖ បាទ!

សេងគា ៖ ចុះម្តាយឈ្មោះអីពូ?

ធឿន ៖ ម្តាយឈ្មោះ គាត់ ធីម ។

សេងគា ៖ គាត់នៅរស់ឬក៏ស្លាប់ហើយ?

ធឿន ៖ ស្លាប់ហើយ ។

សេងគា ៖ ស្លាប់ជាមួយគ្នាហ្នឹងឬក៏?

ធឿន ៖ អត់ទេ ស្លាប់ក្រោយមក ស្លាប់ក្នុងអំឡុងពេល ។

សេងគា ៖ ៨០ជាងឬ៩០ជាង?

ធឿន ៖ ដូច៩០ជាងហើយ ៩៧-៩៨ហើយ ខ្ញុំមិនដែលបានជួបមុខប៉ុនក្នុងកំឡុងពេលប៉ុនហ្នឹង ។

សេងគា ៖ បងប្អូន១១នាក់ហ្នឹងស្រីប៉ុន្មាន ប្រុសប៉ុន្មានពូ?

ធឿន ៖ របុស៦នាក់ ស្រី៥នាក់ ។

សេងគា ៖ កាលហ្នឹងគាត់មានស្លាប់នៅក្នុងសម័យប៉ុល ពតទេ?

ធឿន ៖ អត់ទេ នៅរស់ទាំងអស់ ។

សេងគា ៖ កាលហ្នឹងគាត់នៅជាមួយពូដែរ ឬនៅបែកគ្នាបងប្អូនពូ?

ធឿន ៖ នៅបែកគ្នា កាលហ្នឹងមិនដែលនៅជុំគ្នា កាលជំនាន់៣ឆ្នាំ នៅតាមអង្គភាពរៀងៗខ្លួន ។ មិនដែលនៅជុំគ្នាទេ ឪពុកនៅតែឪពុក បងនៅបង ។

សេងគា ៖ បាទ!មិញពូថាពូចូលរៀនតាំងពីអាយុប៉ុន្មានឆ្នាំពូ?

ធឿន ៖ ខ្ញុំរៀនៗតាំងពីតូចមក រៀនកាលនៅក្មេង ។

សេងគា ៖ រៀនបានថ្នាក់ទី៨?

ធឿន ៖ បាទ!

សេងគា ៖ នៅសាលាបឋមសិក្សាអីគេមិញ?

ធឿន ៖ អេ៎!ខ្ញុំថ្នាក់ទី៨ហ្នឹង គឺថាចូលមកនៅរដ្ឋប្រហារហើយ ថ្នាក់ទី៨ពីដើមហ្នឹង ។

សេងគា ៖ ថ្នាក់ទី៨ចូលវិទ្យាល័យហើយ?

ធឿន ៖ បាទ!វិទ្យាល័យ ។ វិទ្យាល័យយកថ្នាក់ទី៦ធ្វើវិទ្យាល័យ ថ្នាក់ទី៦បានទី៥ទី៤ ។ ថ្នាក់ទី៨រៀនបានតែប៉ុន្មានឆ្នាំវារដ្ឋប្រហារឆ្នាំ៧០ហើយ ។

សេងគា ៖ បាទ!វិទ្យាល័យឈ្មោះអីគេពូកាលហ្នឹង?

ធឿន ៖ ព្រះកុសមៈក្រចេះ តែឥឡូវមិនដឹងដាក់ឈ្មោះអីគេទេ មិនដែលដឹង ។

សេងគា ៖ ម៉េចបានឈប់រៀនពូ?

ធឿន ៖ ពេលហ្នឹងរដ្ឋប្រហារៗវាច្របូកច្របល់ មានសាលាណារៀនទៀត ថ្នាក់រៀនឈប់រៀនទាំងអស់ ។ សាលានៅក្នុងតំបន់រំដោះហ្នឹងគឺថាបិទទាំងអស់ អត់មានសាលារៀនទេ ។

សេងគា ៖ ឈប់រៀនឆ្នាំ៧០រដ្ឋប្រហារ ។ ដល់ពេលរដ្ឋប្រហារហើយពូទៅណាទៀត?

ធឿន ៖ រដ្ឋប្រហារហើយវាក្រោយឆ្នាំ៧០ ។ ក្នុងពេល៧០-៧១ហ្នឹងខ្ញុំនៅធ្វើស្រែចំការជាមួយឪពុកម្ដាយហ្នឹង ។

សេងគា ៖ អីចឹងដល់១៩៧៣ហ្នឹងពូនៅធ្វើ?

ធឿន ៖ ដល់៧៤ៗ ខាងហ្នឹងគេរើសៗដាក់កងចល័តចូលជាអង្គភាព ចូលអង្គភាពអាហ្នឹងដាច់ចេញពីក្រុមគ្រួសារហើយ ។

សេងគា ៖ ដល់ឆ្នាំ៧៤អ្នកណាគេអ្នកជ្រើសតាំងពូឲ្យធ្វើកងទ័ព?

ធឿន ៖ អត់មានរើសតាំងដាក់កងទ័ពទេ កាលហ្នឹងរើសដាក់កងចល័តទេ កងចល័តសម្រាប់បង្កបង្កើនផល ។

សេងគា ៖ អ្នកណាគេអ្នករើសពូ កាលហ្នឹង ប្រធានភូមិប្រមូលប្ដូម៉េច?

ធឿន ៖ បាទ! អាហ្នឹងប្រធានភូមិគេចាត់តាំងជាក្រុម ឧបមាថា មួយក្រុមៗ ត្រូវក្រុមណាចូលជាកងចល័ត ក្រុមណាចូលទៅអង្គភាព ។ កងចល័តហ្នឹងគេហៅថា កងបង្កបង្កើនផល ។

សេងគា ៖ ប្រធានភូមិហ្នឹងពូមិនចាំឈ្មោះគាត់ទេ?

ធឿន ៖ ភ្លេចអស់ហើយយូរហើយ ។

សេងគា ៖ នៅពេលធ្វើកងចល័តហ្នឹងនៅបាន២ឆ្នាំ ហើយគេឲ្យធ្វើអីខ្លះការងារកងចល័តហ្នឹងពូ?

ធឿន ៖ កងចល័តមានតែធ្វើស្រែចំការ ។

សេងគា ៖ រហូតបាន២ឆ្នាំបានឈប់ឆ្នាំ៧៦ ?

ធឿន ៖ ៧៥ ហ្នឹងជ័យជំនះ១៧ មេសា ។

សេងគា ៖ អីចឹងពី៤មកដល់៧៥ អីចឹង?

ធឿន ៖ បាទ! បានជាង១ឆ្នាំ ។

សេងគា ៖ កាលពេលរំដោះ?

ធឿន ៖ រំដោះឆ្នាំ៧៥ គេឲ្យខ្ញុំកាន់ មិនមែនជាប្រធានគេទេ ជាសមាជិកកាន់កន្លែងផ្គត់ផ្គង់ស្រុកក្រចេះហ្នឹង នៅក្នុងមន្ទីរផ្គត់ផ្គង់ស្រុកក្រចេះ ។

សេងគា ៖ អីចឹងខ្ញុំបកក្រោយបន្តិចពូ កន្លែងកងចល័យមិញគេរើសម៉ាកងចល័តមានគ្នាប៉ុន្មាននាក់ពូ?

ធឿន ៖ កងចល័តហ្នឹងគេរើសច្រើនណាស់ ឧបមាថា គេជ្រើសរើសតាមឃុំហ្នឹងហ្នង ដូចជាឃុំគេជ្រើសរើសជាង១០នាក់ ជាង១០នាក់យកមកធ្វើជាអង្គភាពមួយ ។

សេងគា ៖ ចុះប៉ុន្មានឃុំទៅ គេជ្រើសរើសគ្រប់ឃុំ?

ធឿន ៖ រើសគ្រប់ឃុំគ្រប់ស្រុកកាលហ្នឹង ។

សេងគា ៖ កាលហ្នឹងមានប៉ុន្មានឃុំ?

ធឿន ៖ ស្រុកក្រចេះកាលហ្នឹងមានប៉ុន្មានឃុំទេ ដូចជា៧-៨ឃុំ ចាំមិនបានទេជំនាន់ហ្នឹងឃុំវាច្រើនដែរ ។

សេងគា ៖ បាទ!ដល់ពេលរើសមេឃុំ១០នាក់អីចឹង បញ្ចូលគ្នាបានទៅជាមេអង្គភាពមួយ?

ធឿន ៖ បាទ! បានអង្គភាពមួយ ។

សេងគា ៖ ហើយអត់ដឹងថាអ្នកណាគេអ្នកកាន់អង្គភាពហ្នឹងទេ?

ធឿន ៖ ភ្លេចឈ្មោះគាត់ហើយ យូរហើយ ។

សេងគា ៖ ចុះអនុប្រធានអី?

ធឿន ៖ អត់ចាំទេ យូរហើយ ។

សេងគា ៖ ចុះអ្នកនៅក្នុងកងមួយៗមានចាំខ្លះទេ?

ធឿន ៖ ច្រើនគ្នាទៅភ្លេចភ្លាំងអស់ហើយ វាលែងនឹកនាប្រវត្តិហ្នឹង ។

សេងគា ៖ នៅក្នុងមន្ទីរផ្គត់ផ្គង់ខាងកសិកម្មពូ?

ធឿន ៖ ផ្គត់ផ្គង់ខាងទ្រព្យរបស់ដែលចែក របស់ណាដែលដឹកយកចេញពីទីក្រុងអីចឹងទៅ ។

សេងគា ៖ ដូចជាភស្តុភារក៏ម៉េច?

ធឿន ៖ អាហ្នឹងដូចជាភស្តុភាហ្នឹង សម្រាប់ផ្គត់ផ្គង់របស់សំភារៈ ស្អីចានឆ្នាំងអីនៅតាមសហករណ៍ កាលជំនាន់ហ្នឹងគេថា កាលពីរំដោះភ្នំពេញហើយគេដឹកជ័យភ័ណ្ឌ របស់របរចេញពីភ្នំពេញទៅចែកទៅតាមសហករណ៍ ហើយនេះគ្រាន់តែមានតួនាទីជាសមាជិកគេទេ ខាងក្រោមគេឲ្យយើងជួយចែកចាយទ្រព្យរបស់ហ្នឹង ព្រោះយើងចេះលេខចេះអាគាក់អី ។

សេងគា ៖ អាហ្នឹងនៅខេត្តពូ?

ធឿន ៖ នៅស្រុក ។

សេងគា ៖ នៅពេលហ្នឹងគេប្រមូលរបស់របរហ្នឹងមកទុកផ្តុំនៅកន្លែង?

ធឿន ៖ អត់ទេ!គេថាគេតាមបណ្តាញគេឧបមាថា តំបន់គេចែកមកស្រុក ហើយដល់ស្រុកចែកទៅតាមឃុំ ឃុំគេចែកទៅតាមសហករណ៍បន្តទៀត ។ ឧបមាថា មានរបស់អីបើកមកពីណាអីចឹង តំបន់គេចែកមកស្រុក ហើយស្រុកគេមានតួនាទីចែកនៅតាមឃុំ បានឃុំគេបែងចែកមកតាមសហករណ៍ទៀត ។

សេងគា ៖ បាទ!កាលហ្នឹងគេចែកមានរបស់របរអីគេខ្លះពូ?

ធឿន ៖ របស់របរមានដូចជា ក្រណាត់ មានជាចាន មានឆ្នាំង របស់របរប្រើប្រាស់តាមសហករណ៍ហ្នឹង របៀបប្រជាជនកាលហ្នឹងដូចថា មានតែប៉ុនហ្នឹងឯង អត់មានអី ។

សេងគា ៖ ចុះប្រធានតំបន់ពូមានចាំឈ្មោះអីទេ?

ធឿន ៖ ប្រធានតំបន់ឈ្មោះ យី ហើយក្រោយមកបានមួយភ្លែតៗស្លាប់អស់ហើយ ។

សេងគា ៖ ចុះប្រធាននៅស្រុកលោកពូឈ្មោះអី?

ធឿន ៖ ឈ្មោះ លន គាត់ស្លាប់ដែរគេយកទៅសម្លាប់ដែរ ។

សេងគា ៖ ហើយអនុប្រធានមានចាំទេពូ បន្ទាប់ពីលន មក?

ធឿន ៖ បន្ទាប់ពីលន មកកាលហ្នឹងមាន លុយ នៅជាប់កន្លែងមន្ទីរហ្នឹង ។ មានប្រធានសេដ្ឋកិច្ចផ្សេង ប៉ុនដល់នេះគឺថាកន្លែងមន្ទីរផ្គត់ផ្គង់មានតែឈ្មោះ ឡូយ ហ្នឹង ។

សេងគា ៖ ហ្នឹងនៅមន្ទីរសេដ្ឋកិច្ចពូហ្នឹង?

ធឿន ៖ បាទ!

សេងគា ៖ ប៉ុន្តែពូនៅខាងផ្គត់ផ្គង់?

ធឿន ៖ ផ្គត់ផ្គង់ ។

សេងគា ៖ មន្ទីរសេដ្ឋកិច្ចប្រធានឈ្មោះអីគេពូ?

ធឿន ៖ ម៉ាជំនាន់ហ្នឹងវាមានឈ្មោះ វ៉ិត ឥឡូវស្លាប់ដែរអស់ហើយ ។

សេងគា ៖ ហើយនៅខាងមន្ទីរសេដ្ឋកិច្ចទាំងអស់ហ្នឹង ខាងផ្គត់ផ្គង់មានគ្នាប្រហែលប៉ុន្មាននាក់ដែរពូ?

ធឿន ៖ កាលហ្នឹងដូចជាអង្គភាពមានច្រើនដែរ អង្គភាពផ្គត់ផ្គង់មានគ្នាប្រហែលជា៣០-៤០នាក់ ។

សេងគា ៖ ហ្នឹងតែអង្គភាពផ្គត់ផ្គង់មួយទេ?

ធឿន ៖ បាទ!មន្ទីរផ្គត់ផ្គង់មានគ្នា៣០-៤០នាក់ហ្នឹង ហើយមានបែងចែកតាមផ្នែកៗទៀត ។

សេងគា ៖ មានផ្នែកអីខ្លះ?

ធឿន ៖ មន្ទីរផ្គត់ផ្គង់មានផ្នែកចែកចាយរបស់របរ ផ្នែកបង្កបង្កើនផល មានច្រើនផ្នែកទៀត ។

សេងគា ៖ ចុះផ្នែកទៅរកត្រីសាច់អី?

ធឿន ៖ អាហ្នឹងមានមន្ទីរនេសាទគេផ្សេងទៀត ។

សេងគា ៖ អូ!មន្ទីរនេសាទផ្សេងទេ?

ធឿន ៖ បាទ!វានៅក្នុងផ្គត់ផ្គង់ដែរ នេសាទយកមកចែកដល់នេះយកមកផ្គត់ផ្គង់ ចែកទៅតាមមន្ទីរទៀតទៅតាមសហករណ៍ផ្សេងៗ ពេលណាដែលយើងរកត្រីរកអីបានច្រើនអីចឹង ។

សេងគា ៖ បាទ!អ៊ីចឹងពូនៅក្នុងមន្ទីរផ្តត់ផ្គង់ហ្នឹង បានប៉ុន្មានឆ្នាំដែរ?

ធឿន ៖ ខ្ញុំនៅបានប្រហែលជិត២-៣ឆ្នាំ មើល!៧៥-៧៦-៧៧ នៅប្រហែល៣ឆ្នាំ ។

សេងគា ៖ នៅបានប្រហែល៣ឆ្នាំ អ៊ីចឹងពី៧៥មកដល់៧៨ពូ?

ធឿន ៖ បាទ!ខ្ញុំមក៧៨ អាហ្នឹងក្រោយពី គេយកពុកខ្ញុំដាក់មន្ទីរឃុំឃាំងថាខ្ញុំជាប់និន្នាការ ដល់ជាប់និន្នាការគេត្រូវដកខ្ញុំពីអាមន្ទីរផ្តត់ផ្គង់ទៅកងចល័តទៀត ។

សេងគា ៖ អ្ហូ!កាលដែលគេចាប់ឪពុកពូ ពូនៅហ្នឹងដែរទេ?

ធឿន ៖ ប៉ុនមិននៅជាមួយគ្នាទេ គ្រាន់តែដឹងដំណឹងថាគេចាប់ ។

សេងគា ៖ ដឹងដំណឹងតាមរយៈអ្នកណាទៅ?

ធឿន ៖ កាលហ្នឹងគ្រាន់តែដឹងភ្លាម តាមរយៈណាណីទេ គេដឹងហ្នុង ។

សេងគា ៖ គេដឹង ពូជាប់និន្នាការទៅ?

ធឿន ៖ ជាប់និន្នាការ មានឪពុកម្តាយមានប្រវត្តិមិនល្អអ៊ីអ៊ីចឹង ដល់អ៊ីចឹងគេថាដកយើងចេញពីមន្ទីរផ្តត់ផង់ហ្នឹង ទៅកងចល័ត ។ កងចល័តមិននៅជិតទេ កាលហ្នឹងកងចល័តទៅកសាងកន្លែងមួយនៅឆ្ងាយ តំបន់គ្រុនចាញ់អីហ្នឹងទៅដាក់នៅហ្នឹង ទៅដាក់គ្នាច្រើន មិនមែនតែយើងម្នាក់ទេ គេចំរាញ់ ។

សេងគា ៖ ទៅនៅកងចល័តវិញ?

ធឿន ៖ បាទ! ទៅនៅកងចល័ត ។

សេងគា ៖ ឈ្មោះ ឡួយ ហ្នឹងអ្នកដកពូ?

ធឿន ៖ អត់ទេ បងឡួយអត់មាន កាលហ្នឹងមានគណៈស្រុកថ្មីមកទៀត កាលហ្នឹងគេមិននេះទេ ដូចជាគេចំរាញ់យើង ។

សេងគា ៖ គណៈស្រុកឈ្មោះអីគេពូ មកថ្មីហ្នឹង?

ធឿន ៖ កាលហ្នឹងឈ្មោះ ភ្លេចអស់ហើយ យូរដែលហើយ ។

សេងគា ៖ មិនចាំទេ?

ធឿន ៖ បាទ!មិនចាំទេ ដូច្នេះយកធ្វើជាឯកសារមិនបានទេ វាភ្លេចភ្លាំងច្រើន ។

សេងគា ៖ អត់អីទេ ។ អ៊ីចឹងក៏ដកឲ្យពូមកនៅកងចល័តវិញ មកនៅកន្លែងណាវិញទៅ?

ធឿន ៖ កងចល័តទៅនៅខ្វាំងពី ។ តំបន់ហ្នឹងតំបន់លត់ដី ។

សេងគា ៖ ខ្វាំងពី?

ធឿន ៖ បាទ!ខ្ទាំងពី គេហៅភូមិមួយរយពីដើមគេហៅភូមិមួយរយ ប៉ុនឈ្មោះពីដើមហៅ ខ្ទាំងពីៗ ប៉ុនសុទ្ធតែព្រៃសុទ្ធ ។ ខ្ទាំងពីហ្នឹងកន្លែងដាកន្លែងដែលគេដកអ្នករដ្ឋការ ។

សេងគា ៖ ខ្ទាំងពីហ្នឹងនៅស្រុកអីគេដែរ?

ធឿន ៖ នៅស្រុកក្រចេះហ្នឹងប៉ុនវាំនៅជនបទស្រុកហ្នឹង ។

សេងគា ៖ តំបន់គ្រុនចាញ់ពូ?

ធឿន ៖ បាទ!ជាតំបន់គ្រុនចាញ់ ។ ប៉ុនតំបន់នៅឃុំហ្នឹង គេបង្កើតឡើងពីមុនព្រៃសុទ្ធ ។ អស់ព្រៃទៅគេយកពួកអ្នករដ្ឋការដែលមានសមាសភាពជាប៉ូលីស ជាទាហានអីគេយកទៅដាក់ ហ្នឹងទាំងអស់ ក្រុមគ្រួសារដែលមាននិន្នាការជាប៉ូលីស ជាទាហានគេយកទៅដាក់ហ្នឹង ហើយក្រោយមកបានគេយកសមាសភាពដែលមិនល្អដូចជាពួកខ្ញុំអីចឹងយកទៅដាក់ហ្នឹងទៀត ដើម្បីបង្កបង្កើនផល ទៅលត់ដឹកសាងខ្លួនបង្កបង្កើនផលនៅកន្លែងនោះ ។

សេងគា ៖ ហើយចុះចំណែកឯឪពុកម្តាយបងប្អូនពូនោះ យកទៅដាក់ខាងណាវិញទៅ?

ធឿន ៖ កាលហ្នឹងយើងជិនាន់៣ឆ្នាំ អត់មាននៅផ្ទះខ្លួនឯងទេ ផ្ទះខ្លួនឯងមានប៉ុនដល់នេះគេយកដាក់តាមសហករណ៍ គេចេះតែបញ្ជូនទៅនេះបញ្ជូនទៅនោះ ម្តងទៅនេះម្តងទៅនោះទៅ ។

សេងគា ៖ បែកគ្នាអស់ទៅ?

ធឿន ៖ បាទ!បែកខ្ញែកគ្នាអស់ហើយបងប្អូន អត់បានជុំគ្នាៗទេ ខ្ញុំនៅតែខ្ញុំ បងខ្ញុំនៅតែបងខ្ញុំទៅ ។

សេងគា ៖ មានដែលធ្វើដំណឹងទាក់ទងគ្នាទេ?

ធឿន ៖ អត់ដែលទេ កាលមិនដែលមានប្រពន្ធ័អីទាក់ទងគ្នាទេ ។

សេងគា ៖ អីចឹងដល់ពេលពូចូលមកកន្លែងតំបន់គ្រុនចាញ់ហ្នឹង នៅខ្ទាំងពីហ្នឹង ពេលដែលពូចូលមកហ្នឹង គេលត់ដំពូបែបណាខ្លះទៅកាលហ្នឹង?

ធឿន ៖ កាលហ្នឹងមានតែបង្កបង្កើនផល ឧបមាថាជាអង្គភាពបង្កបង្កើនផល ធ្វើតែស្រែធ្វើស្រែ ធ្វើចំការ ឧបមាថាគ្នាប៉ុន្មានរយនាក់អីចឹងគេបែកជាកងជាក្រុមអីទៅ ធ្វើស្រែព្រឹកឡើងម៉ោងឡើងម៉ោង៤ម៉ោង៥យើងងើបគោរពទង់ជាតិហើយ បានទៅធ្វើការអត់ទាន់មានហូបចុកអីទេ ធ្វើការដល់ម៉ោង១១ថ្ងៃត្រង់អីទៅ ចប់ការងារបានមកហូប ហូបហើយម៉ោង១អីចុះទៅទៀត បានម៉ោង៤ ម៉ោង៥អីបានឡើងមក អាហ្នឹងធ្វើស្រែធម្មតាធ្វើស្រែ លើកភ្លឺកាប់ព្រៃ កាស់ព្រៃ ។

សេងគា ៖ ចុះប្រធានក្រុមនៅក្នុងកងចល័តឈ្មោះអីទៅ? នៅកងចល័តនៅកន្លែងគ្រូនចាញ់ហ្នឹងពូ នៅកន្លែងខ្ទាំងពីហ្នឹង?

ធឿន ៖ ឈ្មោះ ភេន ស្អីគេទេភ្លេចអស់ហើយ យូរដែលហើយមិនបាននឹកនាផង ។

សេងគា ៖ កាលកងចល័តហ្នឹងបែងចែកជាប៉ុន្មានក្រុម កងចល័តនៅហ្នឹង?

ធឿន ៖ ក្រុមច្រើន ម៉ាកងហ្នឹងវាច្រើនៗជាក្រុមតូចៗ ។

សេងគា ៖ ចុះប្រធានកងហ្នឹងឈ្មោះអី?

ធឿន ៖ វាភ្លេចអស់ ។

សេងគា ៖ អ្ហូ!អីចឹងមានប៉ុន្មានក្រុមទៅ?

ធឿន ៖ អត់ចាំថាប៉ុន្មានទេ ។

សេងគា ៖ ម៉ាកងហ្នឹងមានប្រហែលប៉ុន្មាននាក់ទៅ?

ធឿន ៖ រាប់រយនាក់ កាលហ្នឹងច្រើននាក់ណាស់ ។

សេងគា ៖ ពូនៅក្រុមទីប៉ុន្មានទៅកាលហ្នឹង?

ធឿន ៖ អត់ចាំទេ មកសួរខ្ញុំក្រុមទីអីខ្ញុំមិនចាំទេ ។

សេងគា ៖ អត់អីទេពូ បើអត់ចាំក៏អត់ចាំចុះ ។ ហើយការហូបចុកអីយ៉ាងម៉េចដែរពូ?

ធឿន ៖ ហូបចុកកាលហ្នឹងពិបាកដែរ អាត់ខាត់ដែរហ្នឹង គ្មានមានស្អីទេមានតែបបរ បាយគេ វាល់ចានដាក់តិចៗនាក់ទៅ ។

សេងគា ៖ ហូបបបរហូបយ៉ាងម៉េចទៅ មួយថ្ងៃហូបប៉ុន្មានវែក ម៉ាពេលប៉ុន្មានវែក?

ធឿន ៖ គេវាល់ចាន ម៉ាចានឲ្យយើង ។

សេងគា ៖ ម៉ាចានប៉ុនណាទៅពូ?

ធឿន ៖ ម៉ាចានគេដួសម៉ាពេញឲ្យយើង ។

សេងគា ៖ ម៉ាចានហ្នឹងមានប៉ុន្មានវែកទៅ?

ធឿន ៖ ម៉ាចានជ្រៅដែរ គេដាក់ម៉ាចាន ដូចអត់បានថែមអីទេកាលហ្នឹង ។

សេងគា ៖ បបរខាប់ឬរាវកាលហ្នឹង?

ធឿន ៖ បបរខាប់ល្មមវាមិនខាប់មិនរាវអីដែរ គេមានបបរញ៉ឹកដាងបាយ ។

សេងគា ៖ ហើយពេលថ្ងៃហូបបាយ?

ធឿន ៖ បាទ!

សេងគា ៖ ល្ងាចហូបបាយដែរពូ?

ធឿន ៖ បាទ!

សេងគា ៖ អ៊ីចឹងព្រឹកបបរ ថ្ងៃបាយល្ងាចបាយ?

ធឿន ៖ បាទ!

សេងគា ៖ គេមានបន្ទុំឲ្យធ្វើការយប់ទៀតទេពូ?

ធឿន ៖ ដូចមិនមនទេកាលហ្នឹង តាមកាលៈទេសៈពេលខ្លះមរមារញឹកអីគេឲ្យយើងថែមធ្វើការ ពេលយប់ខ្លះទៅ១ម៉ោង២ម៉ោងអីទៅ ។

សេងគា ៖ ហើយនៅហ្នឹងមានដូចឧទាហរណ៍ដូចថា អ្នកធ្វើការអីគេឲ្យធ្វើ ធ្វើអត់កើតអី ឈឺអីមាន គេធ្វើបាបទេ?

ធឿន ៖ ទេ!អាហ្នឹងដូចជាមិនមានអីទេ គេគ្រាន់តែឲ្យទៅសម្រាក មានមន្ទីរពេទ្យគេព្យាបាល ។

សេងគា ៖ មន្ទីរពេទ្យហ្នឹងមានគេឲ្យថ្នាំព្យាបាលអីទៅពូ?

ធឿន ៖ ខ្ញុំកាលហ្នឹងមិនមានឈឺអីណាស់ណាទេ គ្រាន់តែអ្នកឈឺគេទៅមន្ទីរពេទ្យថ្នាំគេឲ្យមិនដឹង ថ្នាំអីដែរ ។

សេងគា ៖ បាទ!ប៉ុន្តែគេអត់មានធ្វើបាបវ៉ៃដំអីទេ?

ធឿន ៖ បាទៗ!

សេងគា ៖ កាប់សម្លាប់អីអត់មានទេពូ?

ធឿន ៖ គេកាប់សម្លាប់អារឿងគេ ខ្សឹបខ្សៀវគេ ខ្ញុំមិនដែលបានឃើញផ្ទាល់នឹងភ្នែកទេ អាហ្នឹង គេយកទៅណាគេមិនប្រាប់យើងថា អ្ហ៎!អានេះគេយកទៅកាប់សម្លាប់អីអត់ទេ ។ មិន មែនយកទៅកាប់សម្លាប់នៅមុខយើង ឲ្យយើងឃើញនឹងភ្នែកអត់មានទេ ។

សេងគា ៖ អ៊ីចឹង៧៨ពូនៅបានប៉ុន្មាន បានបែកឆ្នាំ៧៩ហ្នឹងហ្មង?

ធឿន ៖ ឆ្នាំ៧៩ វៀតណាមចូលមក ខ្ញុំក៏មកនៅជាមួយអង្គភាពកងទ័ព បែកចេញពីក្រុមកង ចល័តហ្នឹងខ្ចាតខ្ចាយអស់ហើយ ។

សេងគា ៖ បាទ!អ៊ីចឹងមកនៅកន្លែងអង្គភាពទ័ពខេត្តក្រចេះវិញ?

ធឿន ៖ បាទ!តំបន់ក្រចេះហ្នឹង មានបងម្នាក់ឈ្មោះ បឿន ៗគាត់ពីមុនជាអតីតនៅស្រុកហ្នឹង ដែរ ដល់នេះគាត់ទៅនៅធ្វើមេទ័ពនៅនេះហ្នឹង ដល់នេះមកជួបខ្ញុំៗគេយកខ្ញុំទៅនៅ ជាមួយរហូតទៅ ។

សេងគា ៖ ឆ្នាំ៧៩ពូ?

ធឿន ៖ បាទ!ឆ្នាំ៧៩ ។

សេងគា ៈ មេទ័ពឈ្មោះអីមិញ?

ធឿន ៈ ឈ្មោះ បឿន ។

សេងគា ៈ បឿន គាត់មេទ័ពខាងកងពលឬយ៉ាងម៉េច?

ធឿន ៈ ទ័ពតំបន់កាលហ្នឹងដូចជាវរសេនាតូចមិនដឹង វរៈសេនាធំ មិនដឹងជាវរៈសេនាធំៗ មិនទាន់កងពលទេ ជាវរៈសេនាធំៗឬកងពលតូចអីមិនដឹងទេ កាលហ្នឹង ។

សេងគា ៈ អាហ្នឹងកងពលលេខប៉ុន្មានមានចាំទេ?

ធឿន ៈ អត់ទេៗ!អត់ចាំទេ ដឹងតែតំបន់ ។

សេងគា ៈ ពូស្គាល់គាត់ពីពេលណាមកកពូ?

ធឿន ៈ ខ្ញុំស្គាល់គាត់កាលណែ គាត់មកគ្រប់គ្រងនៅកន្លែងមន្ទីរផ្គត់ផ្គង់ក្របេះហ្នឹង ។ កាលហ្នឹងគេដកពីនេះ យកយោធាៗទៅគ្រប់គ្រងកន្លែងហ្នឹង កាលគេគ្រប់គ្រងរាសភាពការណ៍ស្ងប់ស្ងាត់បន្តិច គេដកយោធាទៅសមរភូមិវិញអស់ទៅ ។

សេងគា ៈ កាលហ្នឹងពូធ្វើទាហានទៀត ឬក៏ពូនៅកន្លែងនេសាទទៀត?

ធឿន ៈ នៅធ្វើជាមួយគាត់ហ្នឹង ព្រោះគាត់ស្គាល់ គាត់ចេះតែឲ្យយើងដើរតាមទៅ គាត់មិនដែលយកទៅណាផង ។

សេងគា ៈ អត់បានប្រយុទ្ធ អត់បានរបួសអីទេពូ?

ធឿន ៈ អត់ទេ ។

សេងគា ៈ គេឲ្យកកាន់កាំភ្លើងដែរកាលហ្នឹង?

ធឿន ៈ កាំភ្លើងគេឲ្យកាន់ធម្មតាទេ ប៉ុនមិនដែលបានទៅប្រយុទ្ធទៅណាណីទេ ។

សេងគា ៈ ពេលនៅជាមួយគាត់ ហូបចុកអីគ្រប់គ្រាន់ទេ ឬក៏អត់អីទេ?

ធឿន ៈ បាទ!កាលហ្នឹងយើងខំមើលហូបខ្លួនយើង ដីកដំឡូងដីកអីហូបធម្មតា អត់មានរបបមកពីណា នៅក្នុងព្រៃ មានរបបផ្គត់ផ្គង់ណាទៀតយើងខំប្រឹងរកខ្លួនឯង ដីកក្ដួចដីកដំឡូង ។

សេងគា ៈ កាលហ្នឹងម៉ាកងពលមានគ្នាប្រហែលជាប៉ុន្មាននាក់ទៅពូ ម៉ាវរៈសេនាធំអីហ្នឹង?

ធឿន ៈ ខ្ញុំក្ដាប់មិនបានទេ ខ្ញុំដឹងតែក្នុងក្រុមនិរសាគាត់ហ្នឹង ម៉ាក្រុមហ្នឹងវាមានជាង១០នាក់ ។

សេងគា ៈ និរសា?

ធឿន ៈ បាទ!ឧបមាថា គាត់ជាអ្នកដឹកនាំបុគ្គលម្នាក់អីចឹងទៅ វាត្រូវមានអ្នកដឹកនាំនិរសាជាង ១០នាក់អីនៅជាមួយ ។

សេងគា ៈ បាទ! ហើយពូគាត់ឲ្យធ្វើអីគេ ដើរតាមគាត់ហ្នឹង?

ធឿន ៖ តាមមនុស្សធ្លាប់ស្គាល់គ្នាពីមុន គាត់ចេះតែឲ្យជួយសរសេរអីតិចតួច ។

សេងគា ៖ អីចឹងពូធ្វើជាលេខារបស់គាត់?

ធឿន ៖ បាទ!ធ្វើជាលេខា កត់ត្រាអីៗតិចតួច ។

សេងគា ៖ កាលហ្នឹងកត់ត្រារឿងអីខ្លះពូ កាលហ្នឹងពូកត់ត្រាមានស្អីខ្លះទៅ?

ធឿន ៖ កាលហ្នឹងវាគ្មានស្អីទេ មានតែធ្វើបញ្ជីកងទ័ពមានប៉ុន្មាន សំភារះរបស់របរអីមានប៉ុន្មានៗក្នុងមាំអន្តភាពៗ ។

សេងគា ៖ តែពូអត់ចាំថាកងទ័ពមានប៉ុន្មានៗទេ?

ធឿន ៖ អត់ទេ!អត់ចាំទេ ។

សេងគា ៖ កាលលើកមុនចាំពូ?

ធឿន ៖ បាទ!បោះបង់ចោលយូរភ្លេចអស់ហើយ ។ គ្រាន់តែឲ្យជួយសរសេរអីតិចតួចហ្នឹងគ្មានអី ។

សេងគា ៖ មានសរសេរសំបុត្រអីផ្ញើរតាមទិសាអីទៅណាទៅណី?

ធឿន ៖ អត់ទេ ។

សេងគា ៖ ពូនៅហ្នឹងប្រយុទ្ធជាមួយកងទ័ពវៀតណាម?

ធឿន ៖ បាទ! ហ្នឹងវាម្ខាងម្នាក់ កងទ័ពវៀតណាម ។

សេងគា ៖ ពូនៅខាងជាប់ព្រំប្រទល់រតនៈគិរីហើយស្ទឹងត្រែង?

ធឿន ៖ បាទ!នៅក្នុងព្រៃហ្នឹង ។

សេងគា ៖ ព្រៃកន្លែងហ្នឹងឈ្មោះព្រៃអីគេពូ ព្រំប្រទល់?

ធឿន ៖ ព្រៃហ្នឹងគេហៅថាអ្វីអីទេ ភ្លេចបាត់ហើយព្រៃតូចព្រៃធនោង ប៉ុនមិននៅជាប់ទេ ប៉ុនវាចល័តអានេះម្តងទៅអានោះម្តងទៅ នៅចល័តគ្រប់កន្លែង ។

សេងគា ៖ កាលពេលប្រយុទ្ធគ្នាហ្នឹងមានរបួសមានអីច្រើនទេ កាលហ្នឹងស្លាប់អី?

ធឿន ៖ របួសមានដែរតិចតួច មិនមានប្រយុទ្ធអីធំ គ្រាន់តែវ៉ៃម៉ាប៉ាវៗវាខ្ចិចអស់ វ៉ៃរបៀបឈ្លប វាមានប្រយុទ្ធជាខ្សែត្រៀមណា អ្នកខ្សែត្រៀមគេមានខ្សែត្រៀមប៉ុនខ្ញុំនៅជាមួយអ្នកដឹកនាំអីចឹងគេមិននៅមុខណា គេនៅក្រោយដូចេះគេមានប៉ះពាល់អី ។

សេងគា ៖ ចុះក្រោម បឿន ហ្នឹងមកមានអ្នកណាគេខ្លះ បន្ទាប់ពីបឿន មក?

ធឿន ៖ អត់ដឹង ។

សេងគា ៖ អត់ចាំទេ?

ធឿន ៈ អត់ ។

សេងគា ៈ នៅរហូតដល់៨១ពូ?

ធឿន ៈ បាទ! នៅ៨១ ។

សេងគា ៈ ប្រយុទ្ធគ្នានៅហ្នឹងរហូត?

ធឿន ៈ ឆ្នាំ៨១ហ្នឹងឆ្លងមកខាងលិចទន្លេហើយ ហ្នឹងដងរែក ។

សេងគា ៈ កាល៨១ឆ្លងមក?

ធឿន ៈ បាទ! ខ្ញុំនៅជាមួយគាត់រហូត ។

សេងគា ៈ ឆ្លងពីទន្លេអីមកពូ?

ធឿន ៈ ទន្លេមេគង្គ ។

សេងគា ៈ នៅម្តុំណា?

ធឿន ៈ អូរក្រៀម ។

សេងគា ៈ ចុះមកជិះទូកមកឬហែលទឹកមក?

ធឿន ៈ ទន្លេម្តុំហ្នឹងវាមានទន្លេ៣ ជិះទូកទន្លេ១ ហែលទន្លេ២ ។

សេងគា ៈ ជិះទូកទន្លេណាមួយទៅ?

ធឿន ៈ ទន្លេដែលមានទឹកហូរខ្លាំង ទន្លេជ្រៅអាហ្នឹងជិះទូក ទន្លេដែលមិនសូវហូរអាហ្នឹងនាំគ្នាហែល ។

សេងគា ៈ កាលហ្នឹងបានទូកពីណាជិះ?

ធឿន ៈ កាលហ្នឹងមានទូកជិះមិនដឹងមានទូកពីណា ។

សេងគា ៈ ហើយកងទ័ពផ្សេងទៀតហែលឬក៏យ៉ាងម៉េច?

ធឿន ៈ ហែល ពេលហ្នឹងដូចថាកន្លែងជិះទូកៗទាំងអស់គ្នា កន្លែងហែលៗទាំងអស់គ្នា ។

សេងគា ៈ បាទ! ពូថាទន្លេ៣មានទន្លេអីខ្លះទៅ ទន្លេ៣ហ្នឹង?

ធឿន ៈ ទន្លេធម្មតាទន្លេនៅក្រចេះនោះវាមិនមែនទន្លេមេគង្គតែមួយទេ ប៉ុនដល់ហ្នឹងវាមានកោះច្រើន ដើម្បីឆ្លងកាត់ហ្នឹងឧបមាថា ឆ្លងពីខាងកើតមកវាមានកោះមួយ កោះហ្នឹងហែលពីកោះហ្នឹងបានមានទន្លេៗឆ្លងពីន្លេមកទៀតបានមានកោះមួយទៀត ប្រាំងមាត់ទន្លេមួយទៀតដូច្នេះទន្លេមេគង្គតែមួយទេ ។

សេងគា ៈ ពូមកជាមួយពូធឿន ហ្នឹងដែរ?

ធឿន ៈ បាទ! មកជាមួយគាត់ ។

សេងគា : កាលហ្នឹងទ័ពមកទាំងអស់ពូ?

ធឿន : កាលហ្នឹងមកជាង២០០នាក់ ។ ២-៣រយនាក់មិនដឹងទេកាលហ្នឹង គ្នាវាច្រើនដែរ ។

សេងគា : បាទ!ដល់ឆ្លងមកដល់ហ្នឹងមកដល់កន្លែងភ្នំអីភ្នំដងរែក?

ធឿន : អាហ្នឹងយើងដើរពីមាត់ទន្លេកន្លះខែបានមកដល់ដងរែក ដើរកន្លះខែគ្រាន់តែធ្វើដំណើរ ។

សេងគា : អត់ទាន់ដល់ក្រវាញទេ ដល់ភ្នំដងរែកហ្នុង?

ធឿន : អេ៎!ក្រវាញនៅនេះ ក្រវាញនៅខាងលិចនេះទេ ដងរែកនៅខាងជើងនោះ ។

សេងគា : ម៉េចបានដើរតម្រង់មកដល់កន្លែងហ្នឹងពូ?

ធឿន : តម្រង់កន្លែងទីតាំងអ្នកដឹកនាំនៅកន្លែងហ្នឹង កន្លែងផ្គត់ផ្គង់សេដ្ឋកិច្ច ។

សេងគា : អ៊ូ!អ្នកណាគេនៅកន្លែងហ្នឹង ឈ្មោះអីគេ?

ធឿន : កន្លែងហ្នឹងអ្នកដឹកនាំ ។

សេងគា : ឈ្មោះ រស់ ញឹម មែន?

ធឿន : មិនមែនទេ អ៊ំ សុន សេន ។

សេងគា : មកជួបអ៊ំ សុន សេនហ្នឹងទៅ?

ធឿន : បាទ!កន្លែងហ្នឹងហើយ ។

សេងគា : ពេលមកដល់ក៏បោះទីតាំងនៅជួរភ្នំដងរែកហ្នឹងទៅ?

ធឿន : បាទ!ទីតាំងកន្លែងហ្នឹងគ្នាច្រើនណាស់ ។

សេងគា : កាលហ្នឹងប្រយុទ្ធកំពុងតែក្តៅគគុកពូ?

ធឿន : បាទ!ប្រយុទ្ធក្តៅ ។

សេងគា : ហើយអ្នកមកជាមួយពូមានត្រូវរបួស ត្រូវគ្រាប់អីទេ?

ធឿន : អត់ទេ! អត់មានបាត់គ្នា ដើរមកស្រុះស្រួលរហូតហ្នឹងជាងកន្លះខែ ។

សេងគា : អត់អ្នកណាជាន់មីនជាន់អីទេ កាលហ្នឹង?

ធឿន : អត់អីទេ!មកគ្រាន់តែស្លាប់ម្នាក់ ស្លាប់នារីដែលពេលហែលទឹក ពេលគេរៀបចំមិនទាន់ស្រួលបួលផងគាត់ចុះហែលទឹក លង់ទឹកស្លាប់ម្នាក់ ស្លាប់នារី ។

សេងគា : អីចឹងស្លាប់តែ១នាក់ជាង២០០នាក់ហ្នឹង?

ធឿន : អេ៎!មិនមែន២០០នាក់ទេ ដូច៣-៤រយមិនដឹងកាលហ្នឹងដូចច្រើនដែរ ។

សេងគា : អីចឹងស្លាប់តែម្នាក់ទេ នៅជួរភ្នំដងរែកហ្នឹង?

ធឿន : បាទ!

សេងគា ៖ ដល់អីចឹងទៅនៅភ្នំដងរែកហ្នឹង បោះទីតាំងជំរំនៅហ្នឹងរហូតទាល់តែដល់ឆ្នាំ៨៤ពូ?

ធឿន ៖ បាទ!

សេងគា ៖ ហើយនៅបោះជំរំនៅក្នុងអំឡុងពេលពី ១៩៨១ដល់១៩៨៤ហ្នឹងនៅធ្វើអីខ្លះទៅពូ?

ធឿន ៖ ៨៤នៅតែក្រោយហើយខ្ញុំ ធ្វើជាលេខាគាត់គ្រាន់តែនៅគ្រប់គ្រងសំភារៈដែលគេសម្រាប់ចែកចាយមកកងទ័ពខាងមុខ មកដល់ធ្វើបញ្ជីចែកខោអាវចែកអីចឹងទៅ ឧបមាថាគេបើកពីលើមកបើកមកដល់យើង យើងគ្រប់គ្រងទៅសម្រាប់ចែកក្នុងវរៈសេនាធំ ។

សេងគា ៖ ហើយកាលហ្នឹងបានខោអាវពីណាមក?

ធឿន ៖ ខោអាវកាលហ្នឹងយកមកពីខាងលើៗបន្តទៀត ។

សេងគា ៖ កាលហ្នឹងសុន សេននៅហ្នឹងដែរពូ?

ធឿន ៖ បាទ!គាត់នៅទទួលហ្នឹង ។

សេងគា ៖ ពូបានឃើញសុន សេនដែរ នៅជាមួយគ្នា?

ធឿន ៖ បាទ!

សេងគា ៖ ហើយគាត់ហ្នឹងជាមនុស្សយ៉ាងម៉េចដែរពូ?

ធឿន ៖ ជាអ្នកដឹកនាំ ជាមនុស្សដូចគ្នាហ្នឹង ។

សេងគា ៖ កាចឬស្លូតកាលហ្នឹង?

ធឿន ៖ គាត់ម៉ឺងម៉ាត់ការងារ ។

សេងគា ៖ អីចឹងពូនៅរហូតដល់៨៤ ម៉េចបានពូសម្រេចចិត្តមកប៉ៃលិន?

ធឿន ៖ ទេ!កាលហ្នឹងគេជ្រើសរើសមកខាងជួរភ្នំក្រវ៉ាញនេះៗ ។

សេងគា ៖ អ្នកណាគេអ្នកជ្រើសរើស សុន សេនហ្នឹង?

ធឿន ៖ គេជ្រើសរើសមិនដឹងពីណាទេ ប៉ុនប្រធានកងពូបឿន ហ្នឹងគាត់ថាឲ្យមកៗខាងលើគេត្រូវការជ្រើសរើស ។

សេងគា ៖ ក៏ឲ្យមកៗ ។ មកគ្នាប៉ុន្មាននាក់កាលហ្នឹងមកជួរភ្នំក្រវ៉ាញហ្នឹង?

ធឿន ៖ មកដូចជាប៉ុន្មានទេ ដូចជា៤-៥នាក់មិនដឹង ភ្លេចដែរ ។ យកធ្វើជាឯកសារមិនបានទេសួរមិនបានដិតដល់អីចឹងភ្លេចភ្លាំងៗ ។

សេងគា ៖ អីចឹងមកប្រហែលជា៤-៥នាក់មកជាមួយពូ កាលហ្នឹងជិះអីគេមកឬក៏ដើរមកទេ?

ធឿន ៖ ជិះឡានតាមដីថៃ ។

សេងគា ៖ អ៊ូ!ជិះឡានតាមដីថៃវិញ?

ធឿន ៖ បាទ!

សេងគា ៖ ច្រកភ្នំក្រវ៉ាញហ្នឹងមកពូ?

ធឿន ៖ បាទ!

សេងគា ៖ កាលជិះហ្នឹង ប្រហែលជាប៉ុន្មានថ្ងៃមកដល់ជួរភ្នំក្រវ៉ាញហ្នឹង?

ធឿន ៖ កាលហ្នឹងជិះតែមួយថ្ងៃ ពីព្រឹកមកដល់ល្ងាចដល់ហើយ ។

សេងគា ៖ កាលជិះមកតាមផ្លូវមានគេបាញ់អី?

ធឿន ៖ អត់មានទេ តាមផ្លូវថៃស្រុកថៃគ្មានបាញ់អី ។

សេងគា ៖ ដល់ជិះមកដល់ចូលតាមច្រកថៃហើយ មកជួរភ្នំក្រវ៉ាញហ្នឹង?

ធឿន ៖ បាទៗ!

សេងគា ៖ កាលហ្នឹងបានឡានអីជិះមក ឡានទាហាន?

ធឿន ៖ ឡានថៃ ថៃកាលហ្នឹងយើងត្រូវជាមួយថៃ ដូច្នេះថៃជូនទៅណាមកណាថៃគេជូន ។

សេងគា ៖ អ្ហូ! ថៃអ្នកជូនមកទាំងអស់?

ធឿន ៖ បាទ! ទំនាក់ទំនងល្អជាមួយថៃកាលហ្នឹង ។

សេងគា ៖ ហើយមកដល់ជួរភ្នំក្រវ៉ាញអីចឹង ។ ម៉េចបានពូ គេឲ្យជ្រើសមកហ្នឹងមកធ្វើអីមកភ្នំក្រវ៉ាញហ្នឹង?

ធឿន ៖ កាលហ្នឹងគេឲ្យមកសិក្សារឿងសេដ្ឋកិច្ចដើម្បីពង្រីក សិក្សាលើឯកសារសេដ្ឋកិច្ច ដើម្បីរៀនចេះទៅយកទៅពង្រីកនៅក្នុងអង្គភាពហ្នឹង ប៉ុនដល់រៀនហើយមិនទាន់បានចប់សព្វគ្រប់ វាមានវៀតណាមបុកចូលមកក៏បែកខ្ញែកគ្នាអស់ទៅ ។

សេងគា ៖ យកទៅពង្រីកនៅកន្លែងពូនៅកន្លែងជួរភ្នំដងរែកហ្នឹង?

ធឿន ៖ បាទ! ប៉ុនមិនទាន់បានពង្រីកទេៗ គ្រាន់តែរៀនខ្លួនឯងបានបន្តិចបន្តួច ។

សេងគា ៖ ក៏វៀតណាមវ៉ៃបែកទៅ?

ធឿន ៖ បាទ!

សេងគា ៖ ដល់វ៉ៃបែកហើយពូទៅណាកាលហ្នឹង?

ធឿន ៖ កាលហ្នឹងនៅ ។

សេងគា ៖ ភ្នំដងរែកហ្នឹងអ្នកណាគេអ្នកកាន់ពូ អ្នកណាគេប្រធានមេទ័ព?

ធឿន ៖ អេ៎! ជិនាន់ហ្នឹងមានតែតាម៉ុក មានតែអីហ្នឹងភ្នំដងរែក ។ អានេះមកភ្នំក្រវ៉ាញៗពីណាពីណីទេ កាលហ្នឹង វាច្រើនមេទ័ពច្រើន ។

សេង៉គា : មិញដងវែកមាន សុន សេន ដល់ភ្នំក្រវ៉ាញមានគោ ម៉ុក?

ធឿន : អេស៎!ភ្នំក្រវ៉ាញដូចនៅត្បូងនោះ ។

សេង៉គា : ក្រែងពូមកភ្នំក្រវ៉ាញ?

ធឿន : បាទ!

សេង៉គា : នៅភ្នំក្រវ៉ាញពីណាគេអ្នកកាន់កាប់កាលហ្នឹង?

ធឿន : មិនដឹងពីណាគេ កាលហ្នឹងវាច្រើនពេក យើងនៅក្រោមគេយើងមិនសូវដឹងរឿងមេៗ គ្រប់គ្រង ។

សេង៉គា : ពេលដែលមកតាមផ្លូវខាង សុន សេន មានឲ្យសំបុត្រយកមកបង្ហាញខាងហ្នឹងអត់?

ធឿន : កាលហ្នឹងគេជូនមកយើងអត់ដឹងមានសំបុត្រមានស្នាម កាលហ្នឹងគេជូនដាក់ៗ ។

សេង៉គា : ចុះពេលដែលកំឡុងវៀតណាមវ៉ៃបែក ពូកំពុងធ្វើអីកាលហ្នឹង?

ធឿន : កាលហ្នឹងនៅជាយុទ្ធជនធម្មតាហ្នឹងគ្មានធ្វើអី នៅជាយុទ្ធជនហ្នឹង ។

សេង៉គា : អត់មានវៀតណាមចាប់បានអីទេ?

ធឿន : អត់ទេ!គេឲ្យជួយជញ្ជូនដឹកគ្រាប់រំសេវអី ផ្តល់ឲ្យកងទ័ពនៅមុខអីហ្នឹង ។

សេង៉គា : ដល់បែកពីហ្នឹងមកបានពូត្រឡប់មកប៉ៃលិនវិញ?

ធឿន : បាទ!

សេង៉គា : អីចឹងនៅបាន២-៣ឆ្នាំដែរពូ?

ធឿន : នៅបាន២ឆ្នាំនោះ បានមករស់នៅ៣២ នៅកន្លែងនេះ ។

សេង៉គា : ព្រោះអីពី៨៤ ពូនៅភ្នំក្រវ៉ាញ?

ធឿន : បាទ!

សេង៉គា : អីចឹងនៅរហូតដល់ចូល៨៩បានពូបកមកនេះ?

ធឿន : បាទ!

សេង៉គា : អីចឹង៨៤មកដល់ វាត្រូវ៥ឆ្នាំនោះបានមកដល់ ។ អីចឹងសិក្សាសេដ្ឋកិច្ចហ្នឹងបានច្រើន ដែរពូ?

ធឿន : បានតិចហ្នឹង គ្មានទាន់បានចេះអីផង ។

សេង៉គា : អាល័យជញ្ជូនគ្រាប់ពូ?

ធឿន : បាទ!កាលហ្នឹងគេឲ្យដឹកជញ្ជូនគ្រាប់រំសេវអី វាមានអ្នកប្រយុទ្ធគេផ្សេង ។

សេង៉គា : អីចឹងប្រធានក្រុមពូអ្នកជញ្ជូនគ្រាប់រំសេវឈ្មោះអីគេវិញ?

ធឿន ៖ អត់ចាំ ភ្លេចអស់ហើយ ។

សេងគា ៖ ដល់ពេលបែកអីចឹងទៅ ក៏ពូនាំគ្នារត់មកប៉ៃលិន?

ធឿន ៖ បាទ!នាំគ្នារត់មកខាងប៉ៃលិនវិញ ។

សេងគា ៖ រត់មកគ្នាប៉ុន្មាននាក់ទៅកាលហ្នឹង?

ធឿន ៖ នៅតាមអង្គភាពហ្នឹង ។

សេងគា ៖ កាលពូរត់មកៗប៉ុន្មាននាក់?

ធឿន ៖ កាលពេលរត់មកៗនៅតាមអង្គភាពគេចាត់តាំង មកនៅប៉ៃលិន ។

សេងគា ៖ ប្រធាននៅហ្នឹងអ្នកចាត់តាំង?

ធឿន ៖ បានវៀតណាមបុកចូលប៉ៃលិន បានខ្ញុំមកនៅខាងនេះទៀតទៅ ។ បាននៅមកដល់ឥឡូវហ្នឹងមានដីបង្កបង្កើនផល មានផ្ទះសម្បែងអី ។

សេងគា ៖ ទៅនៅប៉ៃលិនបាន១ឆ្នាំក៏ពូរត់មកនៅនេះទៅ?

ធឿន ៖ បាទ!

សេងគា ៖ នៅប៉ៃលិននៅម្តុំណាកាលហ្នឹង?

ធឿន ៖ នៅម្តុំបឹងព្រលិតម្តុំអីហ្នឹង ។ ភ្លេចអស់ហើយ ភ្លេចភូមិសាស្រ្តអស់ឥឡូវមិនដែលបានទៅផល ។

សេងគា ៖ នៅសាលាក្នុងឬសាលាក្រៅកាលហ្នឹងបឹងព្រលិត?

ធឿន ៖ បឹងព្រលិតនៅផ្លូវពីព្រំមកកាលហ្នឹងវា..។

សេងគា ៖ មកសាលាក្រៅ?

ធឿន ៖ អ៊ើស!សាលាក្រៅនៅខាងជើងនេះ ជិតត្រពាំងព្រលិត បឹងព្រលិតអីមិនដឹងទេ ។

សេងគា ៖ កាលហ្នឹងនៅក្នុងអង្គភាពកងទ័ពពូ?

ធឿន ៖ បាទ!

សេងគា ៖ កងទ័ពឈ្មោះអីមានចាំ?

ធឿន ៖ អត់ទេ!ហើយបានពីហ្នឹងមកបាននៅ៣២ នៅរហូតដល់ឥឡូវហ្នឹងមានផ្ទះសម្បែង ។

សេងគា ៖ នៅសាស្តានេះទៅ?

ធឿន ៖ បាទ!នៅសាស្តា ។

សេងគា ៖ ហើយដល់ពេលវៃបែកអីចឹងក៏រត់មកនេះទៅ?

ធឿន ៖ បាទ!

សេផគា ៖ ប៉ុន្តែពូអត់ជួបបញ្ហាអីធ្ងន់ធ្ងរ?

ធឿន ៖ អត់ទេ!គ្រាន់តែបន្តបង្កើនផលអីធម្មតាដូចគេដូចឯង។

សេផគា ៖ ហើយពេលដែលនៅហ្នឹងអត់មានឃើញចាប់បានចំណាប់ខ្មាំងអីអត់ទេ?

ធឿន ៖ អត់ទេ!

សេផគា ៖ ហើយកាលដែលមកពីក្រវ៉ាញៗមកដល់ប៉ៃលិនហ្នឹង ពូជិះអីមក ជិះតាមដីថៃដែរឬក៏យ៉ាងម៉េច?

ធឿន ៖ កាលហ្នឹងជិះតាមដីថៃរហូតមក។

សេផគា ៖ ទាល់តែពីប៉ៃលិនមកនេះ ជិះតាមដីថៃឬក៏ដីខ្មែរ?

ធឿន ៖ ដីខ្មែរ។

សេផគា ៖ ទាល់ដល់ពេលគេចរចារគ្នាត្រូវទៅ ក៏រស់នៅបានសុខសាន្តទៅ?

ធឿន ៖ បាទ!

សេផគា ៖ ហើយក៏បង្កើនរបរអីដាំ ធ្វើចំការទៅ?

ធឿន ៖ បាទ!

សេផគា ៖ ពូមានកូនប៉ុន្មាននាក់ដែលពូ?

ធឿន ៖ ខ្ញុំមានកូន៣នាក់។

សេផគា ៖ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ធឿន ៖ ប្រុស២នាក់ ស្រី១នាក់។

សេផគា ៖ ហើយពូរៀបការនៅឆ្នាំណាដែរ?

ធឿន ៖ ខ្ញុំរៀបការនៅឆ្នាំ៩០ហើយ នៅចុង៨៩ជិតចូល៩០។

សេផគា ៖ រៀបការហ្នឹងគេផ្សំផ្គុំឲ្យឬក៏រៀបការយើងស្រឡាញ់គ្នាទេ រៀបការមានភ្លេងមានអីទេ?

ធឿន ៖ អត់ទេ កាលហ្នឹងមិនទាន់មានភ្លេងមានអីទេ។

សេផគា ៖ គេផ្សំផ្គុំឲ្យឬក៏យ៉ាងម៉េច?

ធឿន ៖ បាទ!ផ្សំផ្គុំធម្មតា។

សេផគា ៖ កាលហ្នឹងប្រពន្ធពូធ្វើអី?

ធឿន ៖ មានអីគ្នានារីធម្មតាហ្នឹង។

សេផគា ៖ នៅក្នុងកងណា?

ធឿន ៖ នៅក្នុងកងនារីធម្មតា។

សេងគា ៖ អត់មានធ្វើពេទ្យធ្វើអីទេ?

ធឿន ៖ អត់ទេ ។

សេងគា ៖ ប្រពន្ធពូឈ្មោះអីពូ?

ធឿន ៖ ឈ្មោះ សុន រ៉ាត់ ។

សេងគា ៖ ប្រពន្ធពូនៅម្តុំណាដែរ?

ធឿន ៖ នៅខាងតានីនោះ ។

សេងគា ៖ តានីទូកមាស?

ធឿន ៖ បាទ!តានីទូកមាស ។

សេងគា ៖ បាទ!អីចឹងខ្ញុំដូចជាអស់សំនួរចង់សួរពូដែរ ។ ហើយចង់សួរពូទាក់ទងនឹងរឿងមួយដែរ ដូចឥឡូវហ្នឹងខាងតុលាការ គេមានការកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗហ្នឹងពូមានបាន ដឹងទេពូ?

ធឿន ៖ ដឹងមើលតាមទូរទស្សន៍ ។

សេងគា ៖ អ្ហូ!មើលតាមទូរទស្សន៍អីដែរ?

ធឿន ៖ បាទ!

សេងគា ៖ ចុះបើតាមគំនិតរបស់ពូ ពូធ្លាប់ធ្វើការខាងខ្មែរក្រហមដែរ នៅពេលមានការកាត់ទោស អីចឹងពូយល់យ៉ាងម៉េចដែរថាវាល្អដែរ ឬក៏មិនល្អទេ ហេតុអីដែរ? ហ្នឹងជាគំនិតរបស់ ពូ?

ធឿន ៖ ជាគនិតរបស់ខ្ញុំសភាពការណ៍ហ្នឹង ការកាត់ទោសអាហ្នឹងជាការត្រឹមត្រូវហើយ ព្រោះ ឥឡូវវាថា មានបញ្ហាអីដូចថាមានបញ្ហាដូចជាចោទថាកាប់សម្លាប់អីហ្នឹងវាមានជារឿង មួយ ប៉ុនដល់មានកាត់ទោសអីអាហ្នឹង ដូចជាត្រឹមត្រូវរបស់គេហើយគេធ្វើអីចឹង ។

សេងគា ៖ ព្រោះកាត់តែមេធំៗទេ?

ធឿន ៖ បាទ!កាត់តែមេធំៗវាមិនមែនកាត់ទាំងអស់ បែងចែកថាខ្មែរក្រហមត្រូវតែកាត់ទោស ទាំងអស់អត់ទេ ។

សេងគា ៖ អីចឹងពូគិតថាត្រឹមត្រូវហើយ អត់អីទេ?

ធឿន ៖ បាទ!ត្រឹមត្រូវ ។

សេងគា ៖ ពូគាំទ្រដែរឬអត់ទេ?

ធឿន ៖ អារឿងហ្នឹងគាំទ្រ ក្នុងឋានៈយើងប្រជាជនធម្មតាអត់អីទេ គ្មានទាស់ខុសអីទេ ។

សេងគា ៖ បាទ! ថ្ងៃនេះថ្ងៃទី២១ ខែ៣ ឆ្នាំ២០១១ ។ អីចឹងជាចុងក្រោយពូមានអីចង់និយាយបន្ថែមនូវអ្វីដែលខ្ញុំអត់ទាន់បាននិយាយ មានប្រសាសន៍អីខ្វះទេពូ?

ធឿន ៖ ដូចមិនមានអីទេ ក្នុងឋានៈជាប្រជាជនគ្រាន់តែចង់ រស់នៅបង្កបង្កើនផលធម្មតា ចង់បានសេចក្ដីសុខស្រួលកុំឲ្យមានបញ្ហាទំនាស់ទាស់តែងក្នុងសង្គមអីទៀត ព្រោះការដែលមានវិបត្តិក្នុងសង្គមទាស់ទែងវាមានបែងចែក ខាងនេះខាងនោះអីចឹងធ្វើឲ្យប្រជាជនដែលរស់នៅវាមានផលលំបាកច្រើន សូម្បីតែសភាពការណ៍ឥឡូវជាមួយថៃ ប្រជាជននៅតាមជាយដែនក៏មានការព្រួយបារម្ភដែរ ។ ហើយអានេះប្រសិនជាស្រុកទេសយើងបានសានត្រានហើយ កុំឲ្យមានបញ្ហាអីកើតមានទៀត ព្រោះយើងធ្លាប់ឆ្លងកាត់មានការវេទនាវេទនាហើយលំបាកណាស់ ។

សេងគា ៖ មានដែលនិយាយប្រាប់កូនចៅទេពូ?

ធឿន ៖ ធ្លាប់និយាយប្រាប់ដែរ ។

សេងគា ៖ ហើយកូនចៅជឿទេ?

ធឿន ៖ អាហ្នឹងធម្មតាវាកើតមកស្រួលវាមិនសូវជឿយើងប៉ុន្មានទេ ។ ដល់យើងធ្លាប់ឆ្លងកាត់បានយើងដឹងថា យើងលំបាកណាស់សង្គ្រាមវាមិនស្រួលទេ ។ ផ្ដាំកូនផ្ដាំចៅកុំឲ្យមានសង្គ្រាមកើតឡើង ព្រោះមានសង្គ្រាមកើតឡើងមានបញ្ហាច្រើនណាស់ រប៉ាត់រប៉ាយបែកបាក់គ្រួសារ ។

សេងគា ៖ ហើយពូឆ្នាំណាទៅបានជួបជុំគ្រួសារ បងប្អូន?

ធឿន ៖ ខ្ញុំអត់ដែលបានជួបជុំទេ តាំងពីបែកគ្នារហូតមក ។ បែកគ្នារហូតដល់ឆ្នាំគេផ្ដាច់ខ្លួនហើយហ្នឹង ផ្ដាច់ខ្លួនហើយបានខ្ញុំទៅលេងស្រុកបានមួយដង ទៅលេងបាន២ដងទៅខាងក្រចេះ ។

សេងគា ៖ ពូអាយុប៉ុន្មានហើយពូ?

ធឿន ៖ ខ្ញុំឥឡូវវា៥៧ហើយ ។

សេងគា ៖ ៥៧ឆ្នាំ កើតឆ្នាំ១៩០០ប៉ុន្មាន?

ធឿន ៖ ១៩៥៥ ។

សេងគា ៖ អីចឹងអរគុណពូច្រើន ដែលពូចំណាយពេលច្រើន អីចឹងខ្ញុំជំរាបលាពូ ។

ធឿន ៖ បាទៗ!

«ចប់»